# អារាម តេហ្សេ

## សំណូមពរសម្រាប់ឆ្នាំ ២០២២

# ការទៅជាអ្នកកសាងឯកភាព

បញ្ហាប្រឈមដ៏ធំនាសម័យឥឡូវនេះមានពីរ គឺកសាងឯកភាព និងបង្កើតទំនាក់ទំនងរវាងគ្នានិងគ្នា។ យើងអាចមើលឃើញជាក់ស្ដែងថា សម័យបច្ចុប្បន្នកំពុងតែរងឥទ្ធិពលផ្សេងៗ ផ្ទុយពីគ្នា។ ម្យ៉ាង មនុស្សលោកយល់កាន់តែច្បាស់អំពីចំណង និងទំនាក់ទំនង ដែលពួកគេមានជាមួយគ្នា និងជាមួយធម្មជាតិទាំងមូល។ ជំងឺរាតត្បាត "កូវិដ-១៩" បានបញ្ជាក់សាជាថ្មីថា យើងជាមហាគ្រួសារតែមួយ៖ បើយើងរងគ្រោះថ្នាក់ជាមួយគ្នាយ៉ាងណា យើងក៏អាចដោះស្រាយបាន ដោយរួមជាមួយគ្នាយ៉ាងនោះដែរ។

ម្យ៉ាងទៀត យើងអាចឃើញថា មនុស្សដាច់ពីគ្នាកាន់តែខ្លាំងឡើងៗ ទាំងក្នុងសង្គម ទាំងខាងនយោបាយ និងខាងសីលធម៌ នាំឲ្យប្រជាជន ប្រទេស និងគ្រួសារបាក់បែកគ្នា។ គ្រីស្តបរិស័ទគេចមិនផុតពីបញ្ហាទាំងនេះទេ ៖ ក្រុមជំនុំនិងព្រះសហគមន៍ក៏រងការបាក់បែកក្នុងក្រុមផ្ទាល់ ឬ រវាងគ្នានិងគ្នា ហើយដោយគេចេះតែអាងលើភាពខុសប្លែករបស់ខ្លួន ការបាក់បែកនេះក៏កាន់តែធ្ងន់ទៅៗ។ គួរស្តាយណាស់ ពីព្រោះយើងអាចពឹងលើភាពសម្បូរបែបរបស់យើងនេះ ដើម្បីផ្ដល់សក្ខីភាពយ៉ាងសំខាន់បំផុតអំពីសន្តិភាព។

សព្វថ្ងៃនេះ ក្នុងប្រទេសមួយចំនួន មិនគ្រាន់តែមានការបែកបាក់រវាងគ្នានោះទេ សង្គមក៏លែងជឿលើក្រុមគ្រីស្តបរិស័ទផងដែរ ជាពិសេសដោយមានការលេចឡើងនូវរឿងបំពាន ទាំងខាងផ្លូវភេទ ទាំងខាងផ្លូវវិញ្ញាណ។ មនុស្សជាច្រើនមានអារម្មណ៍ថា យើងបានក្បត់ជំនឿរបស់គេ។ នៅអារាមតេហ្សេ ក៏ដូចនៅកន្លែងឯទៀតៗ យើងបានរិះគិតអំពីបញ្ហាដ៏ធ្ងន់ធ្ងរទាំងនោះ ដោយមិនខ្លាចក្នុងការទទួលយកការពិត តាំងពីប៉ុន្មានឆ្នាំមកហើយ។ យើងចង់ធ្វើអស់ពីសមត្ថភាព ដើម្បីឲ្យអារាមតេហ្សេក្លាយទៅជាកន្លែងមានសុវត្ថិភាព សម្រាប់យើងទាំងអស់គ្នា (www.taize.fr/protection)។

ព្រះសហគមន៍ និងក្រុមជំនុំត្រូវទៅជាកន្លែងប្រកបដោយមេត្រីភាព សម្រាប់មនុស្សទាំងអស់។ ដើម្បីធ្វើបាននៅថ្ងៃនេះ យើងដាច់ខាតត្រូវតែប្រែចិត្តគំនិត តាមព្រះបន្ទូលដំណឹងល្អ យ៉ាងស្មោះអស់ពីដួងចិត្ត។ ព្រះគ្រីស្តបានបូជាព្រះជន្មផ្ទាល់ ហើយសេចក្ដីស្រឡាញ់របស់ព្រះអង្គនេះជាអណ្ដូងថ្មី ដែលយើងអាចដងកម្លាំងបាន ដើម្បីធ្វើជាបងប្អូននឹងអ្នកដទៃ និងលើកតម្លៃរបស់មនុស្សម្នាក់ៗឡើង ព្រមទាំងថែទាំធម្មជាតិនិងបរិស្ថាន។ ព្រះគ្រីស្តសុំឲ្យយើងរួបរួមជាមួយគ្នា ធ្វើជាសញ្ញាថា ព្រះអង្គបានយាងមកបង្រួបបង្រួមមនុស្សលោក ក្នុងសេចក្ដីស្រឡាញ់របស់ព្រះអង្គ។

សម្រាប់ឆ្នាំ២០២២នេះ ខ្ញុំចង់សំណូមពរ ឲ្យយើងរិះគិតនិងតបឆ្លើយនូវសំណួរនេះ គឺ៖ តើយើងអាចធ្វើអ្វី ដើម្បីឲ្យឯកភាពកាន់តែរីកចម្រើន ក្នុងមហាគ្រួសាររបស់មនុស្សលោក ជាមួយធម្មជាតិ ជាមួយបងប្អូនជិតស្និទ្ធ ក្នុងព្រះសហគមន៍ ឬក្នុងក្រុមជំនុំរបស់យើង ហើយជាទីបំផុតនៅក្នុងដួងចិត្តរបស់ខ្លួន?

*បងប្រុស អាឡូអ៊ីស*

- ក្រោយសំណូមពរទាំង៦នេះ មានអត្ថបទខ្លីមួយ ដើម្បីបន្តការរិះគិតឲ្យស៊ីជម្រៅ។ អត្ថបទខ្លីៗទាំងនេះជាប្រធានបទដែលគេនឹងបន្តពិភាក្សាតាមរយៈគេហទំព័រអ៊ីនធើណេត ឬនៅពេលមានប្រជុំនៅអារាមតេហ្សេ។
- អំពីសំណូមពរទាំង៦នេះ យើងនឹងផ្សាយនូវចំណងជើង ជំពូក និងខនៃព្រះគម្ពីរ ព្រមទាំងមតិយោបល់ដែលភ្ជាប់ជាមួយ តាមប្រពន្ធ័អ៊ីនធើណេតដែរ។ សូមទៅមើល www.taize.fr/bible។

# *ដំណើរបូជនីយេសចរ ដើម្បីការជឿទុកចិត្ត ឆ្នាំ២០២២*

ទោះបីជាមេរោគកូវីដបន្តមានការរាតត្បាត យើងសង្ឃឹមថា យើងអាចបន្តដំណើរបូជនីយេសចរដើម្បីការជឿទុកចិត្ត នៅអារាមតេហ្សេ ក៏ដូចជានៅកន្លែងផ្សេងៗទៀតផងដែរ៖

- អស់រយៈពេលមួយឆ្នាំនេះ ជារៀងរាល់អាទិត្យ នឹងមានប្រជុំជាប្រចាំនៅតេហ្សេ។
- ពីថ្ងៃទី៨ ដល់១៥ ខែឧសភា ឆ្នាំ២០២២ មានបូជនីយេចរនៅប្រទេសអ៊ីស្រាអែល។
- ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២២ មានជំនួបមេត្តាភាពយុវជនរវាងឥស្លាមបរិស័ទ និងគ្រីស្តបរិស័ទ។
- ពីថ្ងៃទី២១ ដល់២៨ ខែសីហា ឆ្នាំ២០២២ មានសប្តាហ៍រិះគិត សម្រាប់អ្នកមានអាយុចាប់ពី១៨ ដល់៣៥ឆ្នាំ ជាពិសេសមានកម្មវិធី ដើម្បីយល់អំពីការការពារជីវចម្រុះក្នុងបរិស្ថានធម្មជាតិ។
- ពីថ្ងៃ ២៨ ខែធ្នូ ឆ្នាំ២០២២ រហូតដល់ ថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ មានប្រជុំទូទាំងទ្វីបអឺរ៉ុប (ទីកន្លែងត្រូវប្រកាសនៅក្រុងទូរីណូ ពេលខាងមុខនេះ)។

# *សំណូមពរទីមួយ ៖ អំណរក្នុងការទទួល*

យើងទាំងអស់គ្នាអាចចូលរួមចំណែក ដើម្បីកសាងអនាគតមហាគ្រួសាររបស់មនុស្ស ឲ្យប្រកបដោយសន្តិភាព និងឯកភាព។ ទីមួយ យើងរាល់គ្នាក៏ត្រូវចងក្រងទំនាក់ទំនងល្អទៅវិញទៅមក។ ក្នុងសម័យពោរពេញដោយទុក្ខលំបាកនេះ ចូរឲ្យយើងយកចិត្តទុកដាក់ដល់អ្នកដទៃ ជាពិសេស ក្នុងគ្រួសារផ្ទាល់ និងក្នុងចំណោមបងប្អូន និងមិត្តភក្តិរបស់ខ្លួនផង។

ឯកភាពក្នុងមនុស្សលោកនឹងកាន់តែរីកចម្រើនឡើង រាល់ពេលដែលយើងព្រមបើកចិត្តដល់អស់អ្នកដែលជាមនុស្សចម្លែក ខុសប្លែកពីខ្លួនយើង។ តើយើងមិនគួរទៅរកអ្នកដទៃឲ្យបានច្រើន ជាពិសេសអស់អ្នកដែលយើងមិនសូវចង់ជួបនោះទេ ? សូមកុំឲ្យឆ្ងល់ ! យើងនឹងទទួលពីគេហួសពីការប៉ាន់ស្មានទាំងឡាយរបស់ខ្លួន។

បើភាពសង្ស័យនិងការភ័យខ្លាចមិនធ្វើឲ្យយើងស្ពឹកចិត្ត យើងនឹងទទួលពីគេទាំងមានអំណរសប្បាយដ៏អស្ចារ្យ។ យើងទទួលអត្តសញ្ញាណយើងផ្ទាល់ពីការទាក់ទងជាមួយអ្នកដទៃ គេក៏អាចជួយយើងក្នុងពេលព្រួយចិត្ត ហើយគេអាចធ្វើឲ្យជីវិតរបស់យើងមានអត្ថន័យផងដែរ។

ក្នុងពាក្យប្រស្នាមួយ ព្រះយេស៊ូធ្លាប់រៀបរាប់អំពីជនរងគ្រោះម្នាក់ ដែលជនជាតិបរទេសម្នាក់ទៀតបានសង្គ្រោះ។ ពេលនោះ ជនជាតិដទៃនោះបានធ្វើកាយវិការ ដែលឆ្លងដែនកំណត់ទាំងប៉ុន្មាន ខាងជាតិ ខាងនយោបាយ និងខាងសាសនា។ តើកិច្ចការប្រកបដោយធម៌មេត្តាដែលគាត់បានធ្វើ នៅពេលចាត់ទុកខ្លួនជាបងប្អូននឹងជនរងគ្រោះនៅថ្ងៃនោះ មិនបានផ្តល់អត្ថន័យដល់ជីវិតរបស់គាត់ទេឬ? សព្វថ្ងៃនេះ យើងនៅតែនឹកពី "ជនជាតិសាម៉ារីដ៏សប្បុរស" នេះ ហើយកិច្ចការរបស់គាត់នៅតែបំភ្លឺយើងជានិច្ច (លក១០,២៩-៣៧)។

«យើងមានពាក្យពេចន៍មួយ គឺពាក្យ "អ៊ូប៊ូនទូ"។ ពាក្យនេះសម្តៅទៅលើសភាវៈរបស់មនុស្ស។ ជាពិសេស ពាក្យ "អ៊ូប៊ូនទូ" ចង់ពន្យល់ថា មនុស្សមិនអាចមានជីវិតរស់នៅដោយនៅតែម្នាក់ឯងបានទេ។ "អ៊ូប៊ូនទូ" បង្ហាញថា មនុស្សទាំងអស់ត្រូវតែជាប់ជាមួយគ្នា។ ជាធម្មតា យើងគិតថា ខ្លួនយើងជាបុគ្គលដាច់ឡែកពីគ្នា ក៏ប៉ុន្តែតាមពិត យើងជាប់ជាមួយគ្នាដោយទំនាក់ទំនងជិតស្និទ្ធ ហើយកិច្ចការរបស់យើងតែងតែប៉ះពាល់ពិភពលោកទាំងមូល»

*ពីលោកអភិបាល ដេស្មុន ទូទូ*

*ជាអភិបាលព្រះសហគមន៍ និកាយអង់គ្លីកង់ នៅប្រទេសអាហ្វ្រិកខាងត្បូង*

# *សំណួមពរទីពីរ ៖ អាទិភាពនៃការសន្ទនា*

ឯកភាពអាចរីកចម្រើនបាន លុះត្រាតែយើងចងក្រងទំនាក់ទំនងប្រកបដោយការជឿទុកចិត្ត។ ក៏ប៉ុន្តែជាធម្មតា ទំនាក់ទំនងរវាងមនុស្សរងការគំរាមកំហែង ដោយសារគ្មានការទុកចិត្តចំពោះគ្នាទៅវិញទៅមក។ ការជជែកជាមួយគ្នា ជាពិសេសការពិភាក្សាជាសាធារណៈ និងតាមបណ្ដាញសង្គម កាន់តែពឹងផ្អែកលើអំពើហិង្សា ហើយមានគេបំភ័យប្រជាជន ដើម្បីសម្រេចនូវបំណងរបស់ខ្លួនផងដែរ។ តើយើងអាចធ្វើអ្វី ដើម្បីការពារកុំឲ្យការណ៍នេះបន្តកើតមានឡើងទៀត?

យើងអាចជ្រើសរើសស្ដាប់គេផង និងសន្ទនាជាមួយគេផង។ នេះមិនមានន័យថា យើងត្រូវចុះចាញ់ ហើយយល់ព្រមនឹងគេទេ ថ្វីដ្បិតយើងមានមតិផ្ទុយនឹងគេក៏ដោយ ក៏ប៉ុន្តែយើងត្រូវតែប្រឹងប្រែងឲ្យអស់ពីចិត្ត បន្តការសន្ទនានោះជាមួយអ្នកដែលគិតផ្សេងពីយើង។ ចូរយើងព្យាយាម ដើម្បីចៀសវាងកុំឲ្យផ្ដាច់ការសន្ទនានោះឲ្យសោះ។

ចូរយើងសម្រេចចិត្ត កុំលាបព៌ណ ឬធ្វើបុរេវិនិច្ឆ័យ ទៅលើអ្នកដទៃ។ កុំបង្រួមអត្តសញ្ញាណរបស់គេ តាមតែកិច្ចការ ឬមតិរបស់គេ។ ជាពិសេស ពេលណាយើងជំទាស់នឹងគេយ៉ាងខ្លាំងក៏ដោយ យើងត្រូវសម្ដែងគំនិតរបស់ខ្លួន តាមរបៀបស្លូតបូត មិនប្រើហិង្សា ទោះបីម្ដងៗ ក្នុងសភាពការណ៍អយុត្តិធម៌ខ្លះ គេត្រូវតែបញ្ចេញកំហឹងរបស់គេដែរ។

គំនិតប្រកាន់ជាតិសាសន៍ធ្វើឲ្យសង្គមយើងកាន់តែបាក់បែក ហើយក្រុមគ្រីស្តបរិស័ទក៏ដូច្នោះដែរ។ យើងឧស្សាហ៍ប្រឆាំងនឹងគេ ដើម្បីសម្ដែងអត្តសញ្ញាណរបស់ខ្លួន ប៉ុន្តែផ្ទុយទៅវិញ យើងគួរអភិវឌ្ឍន៍អត្តសញ្ញាណ និងអារម្មណ៍ជាសមាជិក [ក្រុម ជាតិ ប្រទេស សាសនា ។ល។] ដោយមិនបិទទ្វារចំពោះអ្នកដទៃ។

«មេត្រីភាព ពិតប្រាកដនិងជិតស្និទ្ធបំផុត អាចមានរវាងមនុស្សដែលមានគំនិតផ្ទុយគ្នា សូម្បីតែគេមានគំនិតខុសគ្នាលើរឿងសំខាន់មែនទែនក៏ដោយ។ ប្រហែលមេត្រីភាពបែបនេះពោរពេញទៅដោយការឈឺចាប់ ក៏ប៉ុន្តែទុក្ខវេទនានេះធ្វើឲ្យមិត្តភក្តិកាន់តែស្រឡាញ់គ្នាទៅទៀត»។

*ដកស្រង់ពីលោក ចាក់ ម៉ារីតាំង ជាទស្សនវិទូបារាំង នៅឆ្នាំ ១៩៧០*

# សំណូមពរទីបី ៖ ភាពជាបងប្អូននឹងមនុស្សទាំងឡាយ

បើយើងចង់ឲ្យឯកភាពមានការរីកចម្រើន យើងត្រូវបដិសេធ កុំឲ្យមានអយុត្តិធម៌ក្នុងសង្គម។ មនុស្សជាច្រើន ហើយជួនកាលប្រជាជនទាំងមូល ផ្តោតចិត្តគំនិតទៅលើបញ្ហារបស់ខ្លួន ដោយយល់ថា សង្គមធំបានដេញគេចេញ ឬ ដោយគេមានអារម្មណ៍ថា ត្រូវគេបោះបង់ចោល។

ដូច្នេះ ចូរឲ្យគ្រីស្តបរិស័ទគ្រប់និកាយ អ្នកជឿគ្រប់សាសនា និងអ្នកដែលមិនមានសាសនានោះទេ តែមានចិត្តល្អ រួបរួមជាមួយអស់អ្នក ដែលក្រីក្រ ដែលគេបោះបង់ចោល ឬជាជនចំណាកស្រុក ហើយដែលធ្លាប់មានដំណើរជីវិតពោរពេញដោយទុក្ខលំបាកគ្រប់បែបយ៉ាង។

យើងអាចធ្វើជាបងប្អូននឹងអ្នកដទៃ នៅក្នុងគ្រួសារយើងតែម្តង។ ចូរឲ្យយើងហ៊ានរំលងដែនកំណត់របស់ខ្លួន ដើម្បីបង្កើតមេត្រីភាពនៅជុំវិញខ្លួន។ ពេលនោះ ចិត្តរបស់យើងនឹងរីកធំ និងទូលំទូលាយ ហើយមានលក្ខណៈមនុស្សធម៌កាន់តែខ្លាំងជាង។ តើយើងមិនដឹងទេថា របៀបដែលយើងរស់នៅ ក៏អាចប៉ះពាល់ដល់គេ នៅឯចុងកាត់មាត់ញកនៃពិភពលោកដែរ ?

អ្នកជឿមិនអាចបំបែកភាពជាបងប្អូនពីជំនឿបានឡើយ។ ព្រះយេស៊ូធ្លាប់មានព្រះបន្ទូលថា ៖ «អ្វីដែលអ្នករាល់គ្នាបានប្រព្រឹត្ត ចំពោះអ្នកតូចតាចជាងគេបំផុត ដែលជាបងប្អូនរបស់ខ្ញុំ គឺអ្នករាល់គ្នាបានប្រព្រឹត្តចំពោះខ្ញុំ» (មថ ២៥,៤០)។ ព្រះយេស៊ូគ្រីស្តយាងមកក្នុងលោក ដើម្បីរួបរួមជាមួយមនុស្សរាល់គ្នា។ ពេលយើងខិតទៅរកអ្នកដែលបានរងរបួសដោយសារជីវិត គឺយើងកាន់តែជិតស្និទ្ធនឹងព្រះអង្គ។ ពួកគេនាំឲ្យយើងមានទំនាក់ទំនងកាន់តែស៊ីជម្រៅជាមួយព្រះអង្គ។

«បញ្ហាប្រឈមធំនាសម័យនេះ មានដូចតទៅ៖ តើយើងត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីឲ្យមានបដិវត្តន៍ក្នុងចិត្ត ជាបដិវត្តន៍ដែលត្រូវចាប់ផ្តើមចេញពីយើងផ្ទាល់? ពេលណាយើងចាប់យកកន្សែងទាប ដូចជាលាងជើងអ្នកដទៃ និងស្រឡាញ់បងប្អូនយ៉ាងខ្លាំង ដោយសេចក្តីស្រឡាញ់ម្យ៉ាងដែលអាចនាំយើងឲ្យទៅដល់ព្រះឈើឆ្កាង ពេលនោះយើងអាចនិយាយបានយ៉ាងពិតប្រាកដថា ៖ "ឥឡូវនេះ ខ្ញុំបានចាប់ផ្តើមហើយ!"»

*ដកស្រង់ពី ដ្យូជី ខែ ជាអ្នកការសែតជនជាតិអាមេរិក ដែលតស៊ូសម្រាប់សិទ្ធិមនុស្ស នាឆ្នាំ១៩៦៣*

# សំណូមពរទីបួន ៖ ភាពជាផ្នូវតែមួយនឹងធម្មជាតិ

សព្វថ្ងៃ យើងកាន់តែយល់ច្បាស់អំពីឯកភាពនៃធម្មជាតិ ជាស្នាព្រះហស្តរបស់ព្រះជាម្ចាស់។ ធម្មជាតិមានជីវិត និងសភាវៈទាំងអស់ពឹងផ្អែកគ្នាទៅវិញទៅមក ណែនាំឲ្យយើងទទួលស្គាល់ថា យើងជាបងប្អូនរបស់សត្វនិងរុក្ខជាតិទាំងឡាយផងដែរ។ សម្រាប់អ្នកជឿ ផែនដីដ៏អស្ចារ្យរបស់យើងនេះជាព្រះអំណោយទាន ដែលព្រះជាម្ចាស់បានប្រទានឲ្យយើង ដើម្បីបញ្ជូនបន្តឲ្យធ្វើជាកម្មសិទ្ធិដល់អ្នកជំនាន់ក្រោយៗទៀត។

ប៉ុន្តែយើងក៏មើលឃើញដែរថា សកម្មភាពមនុស្សបានបំផ្លាញភពយើងនេះដែរ។ ថ្មីៗនេះ មានកន្លែងជាច្រើនក្នុងពិភពលោក ដែលត្រូវរងគ្រោះមហន្តរាយខាងបរិស្ថាន និងឧបទ្រពខាងអាកាសធាតុ។ ដោយសារវិបត្តិទាំងនេះ មនុស្សកាន់តែច្រើននឹងចាកចេញពីផ្ទះ និងដីធ្លីរបស់ខ្លួន។ មិនត្រឹមតែប៉ុណ្ណោះ តាំងពីយូរឆ្នាំមកហើយ ការស្រាវជ្រាវខាងវិទ្យាសាស្ត្រជាច្រើនទៀតសោត បានជូនដំណឹងអំពីការធ្លាក់ចុះនៃភាពចម្រុះក្នុងធម្មជាតិ។

នាក្នុងគ្រាអាសន្ននេះ ហើយដើម្បីទប់ទល់នឹងវិបត្តិបរិស្ថាន ការតបឆ្លើយខាងនយោបាយ ការផ្លែប្រឌិតថ្មីខាងវិទ្យាសាស្ត្រ និងការជ្រើសរើសរបៀបរស់នៅថ្មីខាងសង្គម ជាអ្វីមួយដែលមិនអាចជៀសវាងបានឡើយ។ យុវជនជាច្រើនប្ដេជ្ញាចិត្តចូលរួមចំណែកជាមួយគ្នាដើម្បីការពារធម្មជាតិ ប៉ុន្តែមួយចំនួនទៀតក៏ខកចិត្ត និងខឹង... ហើយយើងក៏យល់ពីអារម្មណ៍របស់គេដែរ។

កុំធ្លាក់ទឹកចិត្ត ! យើងឧស្សាហ៍ឃើញថា ការផ្លាស់ប្ដូរអាចចាប់ផ្ដើមពី "គ្រាប់ពូជដ៏តូចមួយ" ដែលស្ទើរតែគ្មានសោះ។ ចំពោះអ្នកជឿ ជំនឿរបស់គេជម្រុញដល់ការប្ដេជ្ញាចិត្ត ព្រមទាំងឲ្យគេទុកចិត្តលើសមត្ថភាពរបស់មនុស្ស ដើម្បីរកការតបឆ្លើយនឹងវិបត្តិទាំងនោះ។ ដូច្នេះ យើងអាចសួរខ្លួនឯងថា៖ នាពេលខាងមុខនេះ តើខ្ញុំអាចធ្វើជំហានអ្វីណាសូម្បីតែតូចមួយ ដើម្បីចាប់ផ្ដើមកែប្រែចិត្តគំនិត ឲ្យព្រមការពារបរិស្ថាន (ឬបើខ្ញុំធ្លាប់បានធ្វើខ្លះហើយ ឲ្យខ្ញុំបន្តធ្វើកាន់តែជាក់លាក់តទៅមុខទៀត) ?

«យើងទាំងអស់គ្នា -ទោះបីយើងមានឋានៈអ្វី និងរស់នៅទីណាក៏ដោយ- អាចមានតួនាទី ដើម្បីកែប្រែរបៀបរស់នៅរបស់យើង ហើយតបឆ្លើយនឹងការគំរាមកំហែងថ្មី គឺការផ្លាស់ប្ដូរធាតុអាកាសផង និងការបំផ្លាញបរិស្ថានផង។ ការថែទាំស្នាព្រះហស្តរបស់ព្រះជាម្ចាស់ជាកិច្ចការខាងផ្លូវវិញ្ញាណ ដែលទាមទារឲ្យយើងមានចម្លើយ ប្រកបដោយចិត្តប៉ងប្រាថ្នា។ យើងកំពុងឆ្លងកាត់ពេលវេលាពោរពេញដោយវិបត្តិ។ អនាគតកូនចៅយើង និងអនាគតពិភពលោកយើងអាស្រ័យលើចម្លើយនេះ»។

*ការអំពាវនាវរបស់សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ សម្ដេចជាបិតា បាថូឡូមេ នៃនិកាយអូស្សូដក់*
*និងលោកអភិបាលយុស្ទីន នៃនិកាយអង់គ្លីកង់*

# *សំណូមពរទីប្រាំ ៖ ការប្ដេជ្ញាចិត្តឲ្យគ្រីស្តបរិស័ទគ្រប់និកាយរួបរួមគ្នា*

ការកសាងឯកភាពជាការប្រឈមមួយយ៉ាងធំ ចំពោះគ្រីស្តបរិស័ទ។ តើយើងអាចធ្វើជា"មេម្យៅ"នៃភាតរភាពយ៉ាងដូចម្ដេចបាន បើយើងមិនព្រមបញ្ចប់ការបាក់បែកគ្នាក្នុងខ្លួនយើងដូច្នេះ ? ប្រភពនៃឯកភាពរបស់យើងមានតែមួយគត់ គឺព្រះគ្រីស្ត (យហ ១៧,២០-២១ ; អភ ២,១៤)។ ពេលព្រះគ្រីស្តស៊ូប្ដូរជីវិតនៅលើឈើឆ្កាង ព្រះអង្គបានសម្ដែងសេចក្ដីស្រឡាញ់ដែលគ្មានដែនកំណត់ គឺព្រះអង្គបានរំសាយការស្អប់ និងរំលាយព្រំដែន ដែលមនុស្សបានលើករវាងគ្នានិងគ្នា។

ព្រះបន្ទូលដំណឹងល្អត្រាស់ហៅយើងឲ្យបញ្ចប់ការបាក់បែកទាំងឡាយ ហើយឲ្យផ្ដល់សក្ខីភាពថា ភាពចម្រុះសម្បូរបែបមិនមែនជាឧបសគ្គក្នុងការកសាងឯកភាពទេ។ នេះជាការចូលរួមចំណែក ជាអាទិភាពរបស់គ្រីស្តបរិស័ទ ដើម្បីបង្កើតភាតរភាពក្នុងមហាគ្រួសាររបស់មនុស្សលោក។ សក្ខីភាពនេះអាចមានកម្លាំងខ្លាំងជាងសុន្ទរកថាជាច្រើន។

ព្រះបន្ទូលដំណឹងល្អជម្រុញយើង ឲ្យទៅជាអ្នកមានជំនាញ ដើម្បីបង្កើតឯកភាព។ យើងទាំងអស់គ្នាអាចធ្វើជាអ្នកជំនាញនេះនៅកន្លែងដែលយើងរស់នៅ ដោយចងទំនាក់ទំនងរវាងគ្នា គឺដោយស្ដាប់គ្នា និងស្រឡាញ់គ្នា។

អំពីការសន្ទនារវាងនិកាយគ្រីស្តសាសនា យើងត្រូវចាប់អារម្មណ៍នឹងភាពខុសគ្នាដែលមានជាយូរមកហើយ ហើយក្នុងករណីនេះ ការស្រាវជ្រាវខាងទេវវិទ្យាសំខាន់ណាស់។ ប៉ុន្តែការពឹងទៅលើការសន្ទនាតែមួយមុខ ដើម្បីកសាងឯកភាពជាក់ស្ដែងមិនល្មមគ្រប់គ្រាន់ទេ។

ដើម្បីទៅមុខ ចូរយើងឧស្សាហ៍ជួបជុំគ្នា ជាមួយគ្រីស្តបរិស័ទនិកាយផ្សេងៗ ដើម្បីអធិដ្ឋានរួមគ្នា ដោយយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ធ្វើជាគល់។ ដឹងទេ... ប្រហែលព្រះវិញ្ញាណដ៏វិសុទ្ធនឹងធ្វើឲ្យយើងឆ្ងល់។ យើងនឹងឃើញថា ព្រះយេស៊ូជាព្រះដែលបង្រួបបង្រួមយើង ហើយសេចក្ដីស្រឡាញ់របស់ព្រះអង្គអាចបំភ្លឺយ៉ាងច្បាស់ នៅពេលយើងដាក់ខ្លួននិងទទួលស្គាល់កង្វះខាតរបស់ខ្លួន ព្រមទាំងបើកចិត្តដើម្បីទទួលពីអ្នកដទៃ។

«យើងត្រូវចេះផ្ដល់និងទទួលពីគ្នាទៅវិញទៅមក មិនមែនដើម្បីឲ្យយើងតាមជំនឿរបស់គេទេ ប៉ុន្តែដើម្បីឲ្យយល់ថា និកាយនីមួយៗធ្លាប់ប្រកាសគោលសំខាន់ៗនៃជំនឿរបស់គ្រីស្តទូត ដោយប្រើរបៀបផ្សេងពីគ្នា ប៉ុន្តែដោយមានអត្ថន័យជិតនឹងគ្នាដែរ។ ក្រៅពីការណ៍នេះ យើងត្រូវតែសង្ឃឹមនិងរង់ចាំ ឲ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមកម្ដងទៀត ហើយក៏ត្រូវត្រៀមខ្លួនដើម្បីទទួលព្រះអង្គដែរ»។

*ដកស្រង់ពី លោកស្រី អេលីសាបិត ប៉ែស៊ីហ្គិល ជាទេវវិទូនិកាយអូស្តុដក់ នាឆ្នាំ១៩៨៦*

# សំណូមពរទីប្រាំមួយ ៖ អង្វរព្រះជាម្ចាស់ឲ្យមានឯកភាពក្នុងចិត្ត

ការកសាងឯកភាពទាមទារឲ្យមានការប្ដេជ្ញាចិត្ត អស់ពីកម្លាំងកាយនិងប្រាជ្ញា ហើយការប្ដេជ្ញានេះត្រូវតែចាប់ផ្ដើមនៅក្នុងចិត្តខ្លួនឯង។ យើងសូមអង្វរព្រះជាម្ចាស់ ដោយពឹងលើពាក្យទំនុកតម្កើងថា ៖ «សូមប្រទានឲ្យទូលបង្គំមានចិត្តស្មោះត្រង់ ឬឯកភាពនៃចិត្ត គឺការប្រមូលអង្គវិញ្ញាណនៃចិត្តកុំឲ្យមានការប្រទាញប្រទង់ គោរពកោតខ្លាចព្រះនាមព្រះអង្គ» (ទំន ៨៦,១១)។

យើងមិនអាចសម្រេចឯកភាពនៃចិត្តនេះបានទេ បើសិនជាម្ដងៗ យើងមិនព្រមជ្រើសរើសរវាងការប៉ងប្រាថ្នាទាំងអស់របស់ខ្លួន។ ម្យ៉ាងទៀត យើងក៏ត្រូវទទួលស្គាល់ថា ខ្លួនក៏មិនអាចរស់នៅ ដោយធ្វើតាមរាល់បំណងប្រាថ្នាទាំងអស់របស់ខ្លួននោះឡើយ។ បើយើងមានសមត្ថភាពជ្រើសរើសរវាងជម្រើសច្រើន ចូរយើងរិះគិតដើម្បីយល់ថា តើជម្រើសណានឹងនាំឲ្យមាន សន្តិភាព ពន្លឺ និងសុភមង្គលបានច្រើនជាងគេ។

នៅក្នុងចិត្តយើង មានសេចក្ដីស្រេកឃ្លានអំពីឯកភាព និងការរួបរួមគ្នា ដែលមកពីព្រះជាម្ចាស់ ហើយយើងក៏អាចអង្វរព្រះអង្គ សម្រាប់ការណ៍នេះបាន។ សូម្បីតែយើងមិនសូវចេះនិយាយ យើងក៏អាចនៅស្ងៀមស្ងាត់ រួមជាមួយព្រះអង្គទល់មុខគ្នា។ គ្រាន់តែធ្វើដូច្នេះ យើងនឹងយល់ច្បាស់ជាងអំពីអត្ថន័យនៃជីវិត ហើយចិត្តរបស់យើងនឹងបើកយ៉ាងទូលំទូលាយ ចំពោះកិច្ចការនៃព្រះវិញ្ញាណដ៏វិសុទ្ធ។

ដើម្បីរកឯកភាពនៃចិត្តនេះឃើញ មានផ្លូវមួយ គឺយើងអាចបែរភ្នែករបស់យើងមករកព្រះគ្រីស្ដយេស៊ូ ឲ្យស្គាល់ព្រះអង្គកាន់តែច្បាស់ឡើងៗ ហើយផ្ញើសុខនិងទុក្ខរបស់ខ្លួនទៅឯព្រះអង្គវិញ។ សូម្បីតែយើងកំពុងរងទុក្ខលំបាក ឬមិនដឹងត្រូវគិតយ៉ាងណាអំពីអនាគត ក៏យើងអាចបន្តដំណើរ មួយជំហានម្ដងៗ ដោយជឿតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធថា ព្រះគ្រីស្ដកំពុងតែអម និងធ្វើដំណើររួមជាមួយយើង។

«ភាពស្ងាត់ស្ងៀម នាំឲ្យស្ដាប់ព្រះជាម្ចាស់បាន គឺយើងលុបឧបសគ្គទាំងឡាយ ដែលមិនឲ្យយើងស្ដាប់ឮព្រះអង្គ។ យើងត្រូវស្ដាប់ព្រះជាម្ចាស់ ក្នុងគ្រប់កាលៈទេសៈ ដែលព្រះអង្គសម្ដែងព្រះហឫទ័យ នៅពេលអធិដ្ឋានក៏បាន ក្រៅពីពេលអធិដ្ឋានក៏បាន។ ដើម្បីធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់ យើងត្រូវតែរកភាពស្ងាត់ស្ងៀម ហើយយើងអាចស្ងាត់ស្ងៀមយ៉ាងយូរដែរ គឺ "សមាធិ"។ ក៏ប៉ុន្តែច្រើនលើកច្រើនសារ យើងកាត់ខ្លួនពីសមត្ថភាពនេះ ឬយើងមិនយកចិត្តទុកដាក់។ ពេលយើងអធិដ្ឋានសមាធិ យើង "ប្រមូល" ទាំងដាននិងភស្ដុតាង ទាំងសេចក្ដីអញ្ជើញនិងការបញ្ជា ដែលមកពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដូចអ្នកស្រែប្រមូលស្រូវដាក់ក្នុងជង្រុក ឬដូចអ្នកវិទ្យាសាស្ត្រប្រមូលលទ្ធផលពីការស្រាវជ្រាវរបស់គាត់»។

*ដកស្រង់ពី នាង ម៉ាដឺលែន ដិលប្រិល ជាសកម្មជនសង្គមបារាំង នៅឆ្នាំ ១៩៦៨*